CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន #041920**

ថ្ងៃទី ១៩ ខែមេសាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ក្រសួងពន្លត់អគ្គីភ័យបានចាប់អនុវត្តក្រុមការងារវាយតម្លៃចល័ត

*អ្នកឆ្លើយតបដំបូងនឹងដឹកជញ្ជូនអ្នកជម្ងឺដែលមានលក្ខណៈវិជ្ជមាននិងអាចមានលក្ខណៈវិជ្ជមានចំពោះជំងឺ COVID-19*

ទីក្រុងឡុងប៊ិច,រដ្ឋកាលីហ្វ័រញ៉ា - ក្រសួងពន្លត់អគ្គីភ័យនៅឡុងប៊ិច (Long Beach Fire Department) បានអនុវត្តក្រុមវាយតម្លៃចល័តថ្មី (Mobile Assessment Team) ដែលត្រូវបានចាត់ឱ្យដឹកជញ្ជូនបុគ្គលដែលទទួលបានលទ្ធផលវិជ្ជមានឬបង្ហាញភាពវិជ្ជមាននៃជម្ងឺ COVID-19 ក្នុងការខិតខំដើម្បីទប់ស្កាត់ការរាលដាលនៃជម្ងឺ COVID-19 ដល់អ្នកជំងឺដទៃទៀត បុគ្គលិកមន្ទីរពេទ្យ និងអ្នកឆ្លើយតបដំបូង។ ក្រុមនេះនឹងមានបុគ្គលិកធ្វើការ ១២ ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្តាហ៍។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ក្រុមចល័តថ្មីនេះនឹងធានាថាយើងកំពុងបង្ក្រាប់ការរាលដាលនៃជម្ងឺ COVID-19 តាមដែលអាចធ្វើទៅបានហើយខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងពន្លត់អគ្គីភ័យរបស់យើងដែលបានបង្កើតអង្គភាពថ្មីនេះ។"

ក្រុមវាយតម្លៃចល័តដែលមានអ្នកជំនួយវេជ្ជបណ្ឌិតនៃក្រសួងពន្លត់អគ្គីភ័យឡុងប៊ិចចំនួន ២ នាក់និងរថយន្តសង្គ្រោះបន្ទាន់ ១ គ្រឿងឆ្លើយតបពីទីតាំងកណ្តាលក្នុងទីក្រុងដើម្បីជួយសម្រួលដល់ការឆ្លើយតបយ៉ាងរហ័ស។ ក្រុមនេះក៏ផ្តល់នូវការវាយតម្លៃអ្នកជំងឺ ការព្យាបាល និងការដឹកជញ្ជូនទៅកាន់មន្ទីរពេទ្យ

ក្នុងតំបន់តាមតម្រូវការដែលស្របតាមច្បាប់ពិធីសារសេវាវេជ្ជសាស្ត្របន្ទាន់របស់ខោនធី Los Angeles ។

ប្រធានក្រសួងពន្លត់អគ្គីភ័យឡុងប៊ិចលោក Xavier Espino បានមានប្រសាសន៍ថា "ក្រុមវាយតម្លៃចល័តគឺជាការខិតខំប្រឹងប្រែងយ៉ាងសកម្មដើម្បីគ្រប់គ្រងការរាលដាលនៃជម្ងឺ COVID-19 នៅក្នុងសហគមន៍របស់យើង។ ការបង្កើតអង្គភាពនេះជួយបង្កើនសមត្ថភាពរបស់យើងនិងផ្តល់ធនធានបន្ថែមក្នុងកំឡុងពេលមានវិបត្តិសុខភាពសាធារណៈនេះ។"

ការពិនិត្យដែលមានលទ្ធផលវិជ្ជមានគឺផ្អែកលើបញ្ជីសំណួរអំពីរោគសញ្ញារួមមានគ្រុនក្តៅ ការដកដង្ហើមមិនដល់គ្នា ក្អកឬរោគសញ្ញាស្រដៀងនឹងជំងឺផ្តាសាយធំ។ ក្រុមបញ្ជូននឹងផ្តល់ព័ត៌មានអំពីរោគសញ្ញាទាំងនេះដល់ក្រុមវាយតម្លៃចល័តដែលនឹងប្រដាប់ឧបករណ៍ការពារផ្ទាល់ខ្លួនដែលសមរម្យហើយនឹងប្រុងប្រយ័ត្នពេលកំពុងព្យាបាលនិងដឹកអ្នកជំងឺ។ បន្ទាប់ពីការដឹកជញ្ជូនអ្នកជំងឺនីមួយៗក្រុមការងារនឹងផ្លាស់ប្តូរចេញឧបករណ៍ការពារផ្ទាល់ខ្លួននិងធ្វើនីតិវិធីអនាម័យចាំបាច់សម្រាប់បុគ្គលិកនិងឧបករណ៍។ ដំណើរការអនាម័យនេះនឹងត្រូវបានបញ្ចប់នៅទីតាំងដែលបានកំណត់ទុកជាមុនដើម្បីកាត់បន្ថយការរាលដាលទៅកាន់ឧបករណ៍និងសម្ភារៈផ្សេងទៀត។

ក្រុមវាយតម្លៃចល័តនឹងនៅតែអនុវត្តរហូតដល់មានការជូនដំណឹងបន្ថែម។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

សម្រាប់ព័ត៌មានបន្ថែម រូបភាព វីដេអូ និងសេចក្តីប្រកាសអំពីអ្វីដែលកំពុងកើតឡើងនៅឡុងប៊ិចសូមតាមដានទីក្រុងឡុងប៊ិចនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធូប។

###